## សលាកបត្រព័ត៌មាន ៖ ទំនួលខុសត្រូវរបស់ធុរកិច្ចក្នុងការគោរពសិទ្ធិមនុស្ស

**ទិដ្ឋភាពរួម ៖** ជាផ្នែកមួយនៃកម្រងធុរកិច្ចនិងសិទ្ធិមនុស្ស ដែលពិភាក្សាលើកាតព្វកិច្ចរបស់ក្រុមហ៊ុនសាជីវកម្មក្នុងការគោរពសិទ្ធិមនុស្សនៅពេលដែលពួកគេធ្វើប្រតិបត្តិការ និងការទទួលខុសត្រូវរបស់រដ្ឋដែលទាក់ទងទៅនឹងសកម្មភាពរបស់ធុរកិច្ច មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") សូមបង្ហាញនូវទិដ្ឋភាពទូទៅមួយទាក់ទងនឹងការទទួលខុសត្រូវរបស់ធុរកិច្ចដើម្បីធានាថាប្រតិបត្តិការរបស់ខ្លួន នឹងមិនមានផលប៉ះពាល់អវិជ្ជមានទៅលើសិទ្ធិមនុស្ស។ ជាពិសេស ទិដ្ឋភាពទូទៅនេះបង្ហាញពីជំហានយ៉ាងជាក់លាក់ដែលក្រុមហ៊ុនសាជីវកម្មអាចអនុវត្តតាមបទដ្ឋានឈានមុខលើធុរកិច្ចនិងសិទ្ធិមនុស្ស តាមរយៈគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស។

## សេចក្តីផ្តើម

នៅក្នុងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") ការវិនិយោគពីសំណាក់ធុរកិច្ចជាតិ និងអន្តរជាតិគឺជាកត្តាជម្រុញដ៏សំខាន់មួយសម្រាប់ការអភិវឌ្ឍប្រទេសជាតិ។ យោងតាមធនាគារពិភពលោក[1] ក្នុងរយៈពេលជាង ២០ ឆ្នាំមកនេះ កម្ពុជាទទួលបាននូវ "កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ" ដែលកំណើនសេដ្ឋកិច្ចជាមធ្យមគឺ ៧,៦%។ កំណើនសេដ្ឋកិច្ចនេះរំពឹងថាបន្តកើនឡើងទៀត ទោះបីជាក្នុងល្បឿនយឺតក៏ដោយ គឺអាចក្នុងអត្រា ៧% សម្រាប់ឆ្នាំ២០១៩។[2] ប៉ុន្តែ មានប្រតិបត្តិការរបស់ធុរកិច្ចខ្លះ ជាពិសេសវិស័យសំណង់ និងវិស័យរោងចក្រដែលជាប់ពាក់ព័ន្ធនឹងការប៉ះពាល់សិទ្ធិមនុស្សដូចជាការបំពានលើសុខភាព និងបទប្បញ្ញត្តិសុវត្ថិភាព ការចាប់យកដី ឬការរឹតត្បិតលើសិទ្ធិធ្វើកូដកម្មជាដើម។

បញ្ញត្តិរបស់ "ធុរកិច្ចនិងសិទ្ធិមនុស្ស" សំដៅទៅលើបណ្តុំនៃច្បាប់ និងបទដ្ឋានគតិយុត្តដែលអនុវត្តទៅនឹងសកម្មភាពរបស់ធុរកិច្ច ដើម្បីបញ្ចៀសផលប៉ះពាល់នានាដែលបណ្តាលមកពីសកម្មភាពប្រតិបត្តិការរបស់

---

[1] "កម្ពុជា រក្សាកំណើនរឹងមាំសម្រាប់អត្ថប្រយោជន៍ទាំងអស់គ្នាការវិភាគប្រទេសជាលក្ខណៈប្រព័ន្ធ "ធានាគារពិភពលោក ខែឧសភា ឆ្នាំ២០១៧ ទំព័រ ១០០ https://openknowledge.worldbank.org/bitstream/handle/10986/27149/Cambodia-SCD-May-9-SEPCO-05242017.pdf?sequence=5&isAllowed=y ("របាយការណ៍ធានាគារពិភពលោក ឆ្នាំ២០១៧ ស្តីពីកម្ពុជា")។

[2] "កម្ពុជា សេដ្ឋកិច្ច" ធនាគារអភិវឌ្ឍន៍អាស៊ី https://www.adb.org/countries/cambodia/economy. តាមរយៈការប្រៀបធៀបគម្រោងកំណើនសេដ្ឋកិច្ចនៅបារាំងចំនួន ១.៥% សម្រាប់ឆ្នាំ២០១៩ និង២០២០ (http://www.oecd.org/economy/france-economic-forecast-summary.htm), កំណើនសេដ្ឋកិច្ចជប៉ុន១% (http://www.oecd.org/eco/outlook/japan-economic-forecast-summary.htm) និងនៅកូរ៉េខាងត្បូងចំនួន ៣% (http://www.oecd.org/eco/outlook/korea-economic-forecast-summary.htm).

ពួកគេលើសិទ្ធិមនុស្ស និងត្រូវបានប្រចាប់បញ្ចូលនៅក្នុងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស ("គោលការណ៍ណែនាំ")។[3] មានគោលការណ៍ស្នូលចំនួនបីដែលហៅថា "សសរស្តម្ភ" បានបញ្ជាក់អំពីបញ្ញត្តិនេះ៖ កាតព្វកិច្ចរបស់រដ្ឋក្នុងការការពារប្រឆាំងនឹងការរំលោភសិទ្ធិមនុស្សពីសំណាក់ធុរកិច្ច ទំនួលខុសត្រូវរបស់ធុរកិច្ចក្នុងការគោរពសិទ្ធិមនុស្ស និងកាតព្វកិច្ចទាំងរដ្ឋ និងធុរកិច្ចសម្រាប់ធ្វើឱ្យមានប្រសិទ្ធភាពក្នុងការផ្តល់ដំណោះស្រាយលើករណីរំលោភសិទ្ធិមនុស្ស។ **គ្រប់ធុរកិច្ចទាំងអស់មានទំនួលខុសត្រូវ ដូចៗគ្នាក្នុងការគោរពសិទ្ធិមនុស្សដោយមិនគិតពីម្ចាស់ក្រុមហ៊ុន។** ទំនួលខុសត្រូវរបស់ធុរកិច្ចគឺដើម្បីធានាការគោរពសិទ្ធិមនុស្សដែលគ្របដណ្តប់រាល់សកម្មភាពរបស់ធុរកិច្ចទាំងអស់ទាំងធុរកិច្ចជាតិ ធុរកិច្ចអន្តរជាតិ ធុរកិច្ចពហុជាតិ សម្ពន្ធធុរកិច្ច ធុរកិច្ចបុត្រសម្ពន្ធ ។ល។ និងមិនគិតពីទំហំនៃធុរកិច្ចរបស់ពួកគេ។ គោលការណ៍នេះក៏បានរួមបញ្ចូលទាំងធុរកិច្ចរបស់រដ្ឋ ឬធុរកិច្ចប្រតិបត្តិការតំណាងឱ្យរដ្ឋ (គោលការណ៍ណែនាំ ១៤) ផងដែរ។

សលាកបត្រព័ត៌មាននេះមានគោលបំណងបង្ហាញពីទិដ្ឋភាពទូទៅនៃទំនួលខុសត្រូវរបស់ធុរកិច្ចក្នុងការគោរពសិទ្ធិមនុស្ស។ សលាកបត្រព័ត៌មាននេះ ត្រូវបានរៀបចំឡើងដោយ ម.ស.ម.ក ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ពន្ធ ដែលធ្វើការដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។ គួរកត់សម្គាល់ថា ការទទួលខុសត្រូវរបស់ធុរកិច្ចក្នុងការគោរពសិទ្ធិមនុស្ស ត្រូវបានអនុវត្តគ្រប់ស្ថានការណ៍ថ្វីបើនៅទីតាំងនៃប្រតិបត្តិការនោះមិនមានច្បាប់ជាក់លាក់ ឬការអនុវត្តច្បាប់ខ្វះប្រសិទ្ធភាពក៏ដោយ។ ដូច្នេះមានន័យថា **ទំនួលខុសត្រូវរបស់ធុរកិច្ចដើម្បីធានាការគោរពសិទ្ធិមនុស្សមានភាពឯករាជ្យដាច់ចេញពីកាតព្វកិច្ចរបស់រដ្ឋក្នុងការគោរពសិទ្ធិមនុស្ស។**

## ច្បាប់ពាក់ព័ន្ធ

ប្រតិបត្តិការធុរកិច្ចនៅក្នុងប្រទេសកម្ពុជាត្រូវតែគោរពច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលបានដាក់បញ្ចូលទាំងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងកតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។[4] លើសពីនេះ សន្ធិសញ្ញាប្រទេសកម្ពុជាបានផ្តល់សច្ចាប័នគឺត្រូវបានក្លាយទៅជាច្បាប់ជាតិ និងអនុវត្តដោយផ្ទាល់ក្នុងប្រទេសកម្ពុជា។[5] បន្ថែមពីនេះទៀត ធុរកិច្ចត្រូវគោរពច្បាប់ក្នុងស្រុករួមទាំងច្បាប់ភូមិបាល[6] និងច្បាប់ការងារ។[7] គួរកត់សម្គាល់ថា នៅក្នុង

---

[3] "គោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស៖ ការអនុវត្តក្របខណ្ឌគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស "ការគោរព ការការពារ និងដំណោះស្រាយ" ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ https://www.ohchr.org/Documents/Publications/GuidingPrinciplesBusinessHR_EN.pdf.

[4] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣១

[5] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លេខ ០៩២/០០៣/២០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ https://www.ccc.gov.kh/admin/uploads/dec_2007_92.pdf.

[6] អាចស្វែងរកបានតាមរយៈ http://sithi.org/admin/upload/law/Land%20Law.ENG.pdf.

[7] អាចស្វែងរកបានតាមរយៈ http://www.cambodiainvestment.gov.kh/the-labor-law-of-cambodia_970313.html.

ប្រទេសកម្ពុជា ធុរកិច្ចត្រូវតែទទួលខុសត្រូវលើបទល្មើសព្រហ្មទណ្ឌ។[8] យ៉ាងហោចណាស់ អនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារដែលកម្ពុជាបានផ្តល់សច្ចាប័នបានកំណត់ស្ទើរតែទាំងអស់នោះនូវគោលការណ៍សិទ្ធិមនុស្សសំខាន់ៗទាក់ទងនឹងធុរកិច្ច ដែលទាក់ទងទៅនឹងសិទ្ធិការងារ។[9]

គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស ទោះបីជា មិនមានការចាប់បង្ខំ តែជានិយាមស្របច្បាប់មួយសម្រាប់អនុវត្តចំពោះធុរកិច្ចក្នុងការគោរពសិទ្ធិមនុស្សនាពេលបច្ចុប្បន្ន។ គោលការណ៍ណែនាំនេះផ្តល់នូវមូលដ្ឋានគ្រឹះក្នុងការកសាងនូវការអនុវត្តល្អៗ។ គោលការណ៍ណែនាំលេខ១១ ដល់ ២៤ បានដាក់ចេញនូវគោលការណ៍សំខាន់ៗសម្រាប់ធុរកិច្ចដើម្បីគោរពសិទ្ធិមនុស្សលើវិធីសាស្រ្តពីរយ៉ាង តាមរយៈការជៀសវាងបង្ក ឬការចូលរួមចំណែកបង្កផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្ស ហើយនិងតាមរយៈការបង្ការ ឬការកាត់បន្ថយផលប៉ះពាល់សិទ្ធិមនុស្សដែលកំពុងតែមានស្រាប់ដែលផ្សារភ្ជាប់ទៅនិងប្រតិបត្តិការរបស់ពួកគេ។ លើសពីនេះ គោលការណ៍ណែនាំចាប់ពីលេខ២៩ ដល់ ៣១ ផ្តល់ជាគោលការណ៍ណែនាំដល់ធុរកិច្ចសម្រាប់ផ្តល់ដំណោះស្រាយនៅពេលដែលមានករណីរំលោភសិទ្ធិមនុស្ស។ គោលការណ៍ណែនាំទាំងនោះនឹងត្រូវពិភាក្សាលម្អិតខាងក្រោម។ បទដ្ឋានដែលពាក់ព័ន្ធផ្សេងទៀតរួមមានគោលការណ៍ណែនាំរបស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ[10] គោលការណ៍ណែនាំរបស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍ និងអង្គការស្បៀងអាហារនិងកសិកម្ម សម្រាប់ភាពទទួលខុសត្រូវខ្សែសង្វាក់ផ្គត់ផ្គង់កសិកម្ម[11] និងគោលការណ៍ស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចនៃការកាន់កាប់ប្រកបដោយការទទួលខុសត្រូវ។[12] សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ការបោះពុម្ពផ្សាយរបស់ ម.ស.ម.ក សៀវភៅណែនាំអំពីធុរកិច្ចនិងសិទ្ធិមនុស្សនៅកម្ពុជា។[13]

## តើធុរកិច្ចគួរធ្វើដូចម្តេចដើម្បីគោរពសិទ្ធិមនុស្ស?

[8] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១៨ http://119.15.85.2/2Q2W01004809BA4DDE772510D2F855F17E861B81F2EA_unknown_71E456C0EA2346C06685939EDA8CDFF1FF309FFC_6/sithi.org/admin/upload/law/Criminal_Code_Book_with_cover_Jan_2014.pdf.

[9] អាចស្វែងរកបានតាមរយៈ https://www.ilo.org/global/standards/introduction-to-international-labour-standards/conventions-and-recommendations/lang--en/index.htm.

[10] "គោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ" អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍឆ្នាំ២០១១ http://mneguidelines.oecd.org/guidelines/.

[11] "គោលការណែនាំរបស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ និងអង្គការស្បៀងអាហារ និងកសិសកម្មឆ្នាំ២០១៦ សម្រាប់ភាពទទួលខុសត្រូវខ្សែសង្វាក់ផ្គត់ផ្គង់កសិកម្ម http://www.oecd.org/daf/inv/investment-policy/rbc-agriculture-supply-chains.htm.

[12] "គោលការណ៍ស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចនៃការកាន់កាប់ប្រកបដោយការទទួលខុសត្រូវនៃអង្គការស្បៀងអាហារ និងកសិកម្មរបស់អង្គការសហប្រជាជាតិឆ្នាំ២០១២ http://www.fao.org/tenure/voluntary-guidelines/en/.

[13] "សៀវភៅណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្សនៅកម្ពុជារបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាឆ្នាំ២០១៦ http://cchrcambodia.org/admin/media/report/report/english/2016_Handbook_BHR_English.pdf

ច្បាប់សិទ្ធិមនុស្សផ្តល់សេរីភាពឱ្យរដ្ឋក្នុងការសម្រេចចិត្តលើសកម្មភាពដែលត្រូវធ្វើដើម្បីចាត់វិធានការបញ្ចៀសការរំលោភបំពានសិទ្ធិមនុស្សដោយធុរកិច្ច ដរាបណាវិធានការនោះនឹងមានប្រសិទ្ធភាព។ ប៉ុន្តែ គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ចនិងសិទ្ធិមនុស្សបានផ្តល់ជាអនុសាសន៍មួយចំនួនដូចខាងក្រោមនេះ៖

- អនុម័តយន្តការគោលនយោបាយជាក់លាក់ដែលអាចធ្វើការកំណត់បានយ៉ាងឆាប់រហ័សទៅនឹងករណីនៃផលប៉ះពាល់ ការរំលោភបំពានសិទ្ធិមនុស្សជាក់លាក់ដែលអាចកើតមានចំពោះក្រុមដែលស្ថិតនៅក្នុងហានិភ័យខ្ពស់ជាងគេ ឧទាហរណ៍ ក្រុមជនជាតិដើមភាគតិច (គោលការណ៍ណែនាំ១២)
- រៀបចំសេចក្តីព្រៀង និងផ្សព្វផ្សាយគោលនយោបាយសិទ្ធិមនុស្សឱ្យបានទូលំទូលាយដែលបង្ហាញពីការប្តេជ្ញាចិត្តដើម្បីគោរពសិទ្ធិមនុស្ស (គោលការណ៍ណែនាំលេខ ១៥) ដោយអនុលោមតាមតម្រូវការនៃគោលនយោបាយនៅក្នុងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស (គោលការណ៍ណែនាំលេខ ១៦)
- បង្កើតយន្តការត្រួតពិនិត្យដ៏ត្រឹមត្រូវលើសិទ្ធិមនុស្សដែលអាចកំណត់បានទាន់ពេលនូវករណីរំលោភបំពាន ហើយទទួលបានដំណោះស្រាយ (គោលការណ៍ណែនាំលេខ ១៧)
- ធានាការអនុវត្តសិទ្ធិមនុស្សដែលមានតម្លាភាពនិងបង្ហាញពីភាពជោគជ័យ និងបរាជ័យដល់គ្រប់ភាគីពាក់ព័ន្ធសំខាន់ៗ (គោលការណ៍ណែនាំលេខ ២១)
- បែងចែកធនធានគ្រប់គ្រាន់សម្រាប់ផ្តល់សំណងសមស្របប្រសិនករណីរំលោភបំពានកើតមានឡើង និងបន្តវាយតម្លៃឡើងវិញអំពីប្រសិទ្ធភាពនៃដំណើរការតាមដានសិទ្ធិមនុស្ស (គោលការណ៍ណែនាំលេខ ២០ និង២២)
- អនុម័តនូវនីតិវិធីនានាដើម្បីធានាថានៅពេលដែលមានការរំលោភបំពានសិទ្ធិមនុស្សត្រូវបានគេចាត់ទុកថាទំនងជាកើតមានឡើងព័ត៌មាននេះត្រូវរាយការណ៍ទៅអង្គភាពដែលមានជំនាញក្នុងការដោះស្រាយដើម្បីផ្តល់ដោះស្រាយនៃផលប៉ះពាល់ (គោលការណ៍ណែនាំលេខ ១៩)
- ស្វែងរកអនុសាសន៍ពីអ្នកជំនាញខាងក្រៅលើការកាត់បន្ថយការរំលោភបំពានសិទ្ធិមនុស្ស និងបង្កើតយន្តការសន្ទនាសមស្របមួយដើម្បីអាចអោយក្រុមដែលងាយរងគ្រោះបានចូលរួមជាប្រចាំ (គោលការណ៍ណែនាំលេខ ១៨)

សំខាន់ជាងនេះទៅទៀតនោះ រាល់សកម្មភាពទាំងអស់ដែលបានដាក់ឱ្យអនុវត្តដោយធុរកិច្ចដើម្បីការពារ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្សត្រូវតែតាមដានដើម្បីវាយតម្លៃពីប្រសិទ្ធភាព (គោលការណ៍ណែនាំ លេខ២០)។ ជាពិសេស ការវាយតម្លៃនេះត្រូវផ្តោតសំខាន់លើគោលបំណងនៃសូចនាករ និងត្រូវបានលើកឡើងអំពីការឆ្លុះបញ្ចាំងនៃប្រភពខាងក្នុង និងខាងក្រៅរួមបញ្ចូលទាំងភាគីពាក់ព័ន្ធពីផលប៉ះពាល់នេះ។

## តើធុរកិច្ចគួរធ្វើដូចម្តេចដើម្បីផ្តល់ដំណោះស្រាយនៃការរំលោភបំពានសិទ្ធិមនុស្ស?

គោលការណ៍លេខ ២៥ ដល់ ៣១ នៃគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីធុរកិច្ច និងសិទ្ធិមនុស្សជាពិសេសទាក់ទិននឹងប្រសិទ្ធិភាពនៃការផ្តល់ដំណោះស្រាយសម្រាប់ការរំលោភបំពានសិទ្ធិមនុស្សតាមរយៈធុរកិច្ច។ អ្វីដែលចាំបាច់នោះគឺ ដំណើរការនេះមានភាពមិនលម្អៀង និងយុត្តិធម៌[14] និងផ្តល់ដំណោះស្រាយយ៉ាងមានប្រសិទ្ធភាព ដែលដំណោះស្រាយនេះត្រូវតែលើកយកបញ្ហារំលោភបំពានសិទ្ធិមនុស្សមកដោះស្រាយជាជាងមានតែនីតិវិធី ប៉ុន្តែគ្មានបានលទ្ធផល។ លើសពីនេះ យន្តការនេះត្រូវតែអាចប្រើប្រាស់បាន មានន័យថាគ្រប់បុគ្គលត្រូវតែដឹងពីយន្តការនេះ និងត្រូវតែអាចប្រើប្រាស់យន្តការនេះបាន ដោយគ្មានការលាក់បាំង។[15] ដើម្បីឱ្យមានប្រសិទ្ធភាពពិតប្រាកដ ដំណោះស្រាយត្រូវតែមានភាពប្រទាក់ក្រឡាគ្នាជាមួយការបញ្ឈប់នៃដំណើរការរំលោភសិទ្ធិមនុស្ស។[16] ស្រដៀងគ្នានេះដែរ ចំពោះអ្នកដែលបានត្រូវបានរកឃើញថាមានជាប់ពាក់ព័ន្ធទៅនឹងការរំលោភបំពានសិទ្ធិមនុស្សត្រូវតែបញ្ជូនទៅកាន់ប្រព័ន្ធយុត្តិធម៌របស់រដ្ឋ។[17] យោងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស ធុរកិច្ចក៏ត្រូវតែចូលរួមឱ្យសកម្មផងដែរក្នុងការចាត់វិធានការដើម្បីធានាថាគ្រប់បុគ្គលដែលសិទ្ធិរបស់ខ្លួនទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរពីសំណាក់ប្រតិបត្តិការ ពួកគេអាចទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព។[18] ជាពិសេស ពួកគេគួរតែចូលរួមយន្តការបណ្តឹងនោះឱ្យមានប្រសិទ្ធភាព (គោលការណ៍ណែនាំ លេខ២៩) ដែលផ្តល់ជាតម្រុយសម្រាប់អ្នកដែលត្រូវរងផលប៉ះពាល់ផ្ទាល់ពីប្រតិបត្តិការរបស់ខ្លួនដើម្បីលើកពីកង្វល់របស់ខ្លួន។ អ្នកទាំងនោះក៏ត្រូវបានអនុញ្ញាតឱ្យកំណត់ពីបញ្ហាទាន់ពេលវេលាដើម្បីការទប់ស្កាត់ពីបញ្ហាដែលកើនឡើង។

### ករណីសិក្សា៖ ជម្លោះដីធ្លីជាមួយក្រុមហ៊ុន សុកហ៊ីន ខេស៊ីឌី ស្ថិតនៅឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី

ចាប់តាំងពីឆ្នាំ២០០៨ ក្រុមហ៊ុនកៅស៊ូ សុកហ៊ីន ខេស៊ីឌី បានជាប់ពាក់ព័ន្ធក្នុងវិវាទដីធ្លីជាមួយនឹងសហគមន៍[19]មកពី៦ភូមិ[20] នៅក្នុងឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ដែលស្ថិតនៅភូមិភាគឦសាននៃប្រទេស

[14] គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីធុរកិច្ច និងសិទ្ធិមនុស្សទី២៥

[15] គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីធុរកិច្ច និងសិទ្ធិមនុស្សទី២៦

[16] "មតិយោបល់ទូទៅលេខ ៣១ លក្ខណៈនៃការតព្វកិច្ចផ្លូវច្បាប់ទូទៅ ដែលដាក់ភាគីជារដ្ឋចំពោះអនុញ្ញា" គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ខែឧសភា ឆ្នាំ ២០០៤ កថាខណ្ឌ ១៥ (មតិយោបល់ ទូទៅលេខ ៣១ របស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា) http://docstore.ohchr.org/SelfServices/FilesHandler.ashx?enc=6QkG1d%2FPPRiCAqhKb7yhsjYoiCfMKoIRv2FVaVzRkMjTnjRO%2Bfud3cPVrcM9YR0iW6Txaxgp3f9kUFpWoq%2FhW%2FTpKi2tPhZsbEJw%2FGeZRASjdFuuJQRnbJEaUhby31WiQPl2mLFDe6ZSwMMvmQGVHA%3D%3D.

[17] មតិយោបល់ទូទៅលេខ ៣១ របស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា កថាខណ្ឌ១៨ ។

[18] គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីធុរកិច្ច និងសិទ្ធិមនុស្សទី២៩

[19] ភូមិពូទឹត ភូមិពូរ ាំ ភូមិប៊ូស្រា ភូមិឡាំមេះ ភូមិពូចារ និងភូមិពូលុ។

[20] អាចប្រកបជា ប៊ូស្រា។

កម្ពុជា។ ប្រជាពលរដ្ឋជាង ៨០០គ្រួសារ ត្រូវបានទទួលរងនូវផលប៉ះពាល់[21] ដែលភាគច្រើនគឺជាក្រុមជនជាតិដើមភាគតិចពូនង[22]ដែលមកពីសហគមន៍ជនជាតិដើមភាគតិច។ មកទល់សព្វថ្ងៃនេះ ប្រជាពលរដ្ឋរាប់រយគ្រួសារនៅតែបន្តជាប់ពាក់ព័ន្ធនៅក្នុងដំណើរការនៃដំណោះស្រាយវិវាទដីធ្លីនេះ។

អ្នកភូមិមួយចំនួនដែលមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានសម្ភាសន៍ជាមួយនោះបាននិយាយថា ពួកគេមិនបានចូលរួមពិគ្រោះយោបល់ដោយត្រឹមត្រូវ ឬផ្តល់ព័ត៌មានអំពីគម្រោងនោះទេ ហើយថាដីរបស់ពួកគេត្រូវបានគេរំលោភយក ទ្រព្យសម្បត្តិរបស់ពួកគេត្រូវបានបំផ្លិចបំផ្លាញ ពួកគេត្រូវបានគំរាមកំហែងពីសំណាក់អាជ្ញាធរមូលដ្ឋានខណៈពេលដែលព្យាយាមតវ៉ានឹងប្រតិបត្តិការរបស់ក្រុមហ៊ុន សុកហ្វីន ខេស៊ីឌី ហើយក្រុមហ៊ុនមិនបានផ្តល់សំណងសមរម្យអ្វីនោះទេសម្រាប់ការរឹបអូសយកដីធ្លីរបស់ពួកគេ និងការរំលោភបំពានសិទ្ធិមនុស្សផ្សេងៗជាមួយគ្នានោះ។ តាមបទសម្ភាសន៍ជាមួយអ្នកភូមិបានឱ្យដឹងថា ពួកគេបានបាត់បង់ក្នុងការទទួលផលពីអនុផលធម្មជាតិដូចជាប្រភពទឹក សត្វព្រៃ និងតំបន់នេសាទដែលបង្កឱ្យមានការប៉ះពាល់ដល់ជីវភាពនៃការរស់នៅរួមទាំងការប្រឈមនឹងបញ្ហាសុខភាពបញ្ហាផ្លូវចិត្តដូចជាការបាក់ទឹកចិត្ត និងភាពតានតឹងផ្លូវអារម្មណ៍ជាដើម។

យ៉ាងណាក្តីខុសពីក្រុមហ៊ុនភាគច្រើនពាក់ព័ន្ធនឹងបញ្ហាដីធ្លីនៅកម្ពុជា ចាប់តាំងពីដំណាក់កាលដំបូងក្រុមហ៊ុន សុកហ្វីន ខេស៊ីឌីបានចូលរួមចំណែកយ៉ាងសកម្មក្នុងដំណើរការនៃដំណោះស្រាយវិវាទដីធ្លី។ ទោះបីជាមកដល់ពេលនេះ បញ្ហាជម្លោះទាំងនោះពុំទាន់បានដោះស្រាយចប់សព្វគ្រប់ក្តី ក៏កិច្ចខិតខំប្រឹងប្រែងទាំងនេះគួរត្រូវបានកត់សម្គាល់តាមរយៈការអនុវត្តល្អៗ ដែលមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា សង្ឃឹមថានឹងអាចជួយជម្រុញស្ថាប័ន ឬក្រុមហ៊ុនឯកជនដទៃផ្សេងទៀតអាចអនុវត្តផងដែរ។

សកម្មភាពចម្បងៗរួមមានដូចខាងក្រោម ៖

- ផ្តល់ការបណ្តុះបណ្តាលបុគ្គលិករបស់ក្រុមហ៊ុនសុកហ្វីន ខេស៊ីឌី ស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស និងសិទ្ធិរបស់ជនជាតិដើមភាគតិច។[23]
- ចែករំលែកករណីសិក្សា និងបទពិសោធន៍ល្អៗរបស់ក្រុមហ៊ុនទៅបណ្តាភាគីអ្នកពាក់ព័ន្ធដទៃផ្សេងទៀត៖ នៅខែធ្នូ ឆ្នាំ២០១៧ ក្រុមហ៊ុន សុកហ្វីន ខេស៊ីឌី បានចូលរួមសិក្ខាសាលាស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស និងនិរន្តភាពកសិ-ពាណិជ្ជកម្មនៅខេត្តមណ្ឌលគិរីដែលរៀបចំឡើងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា។ តំណាងក្រុមហ៊ុនសុកហ្វីនកម្ពុជា បានធ្វើបទ

---

[21] "កម្ពុជា - ដីឈូឆាយសម្រាប់ដំណាំកៅស៊ូសិទ្ធិត្រូវបានរំលោភ៖ ផលប៉ះពាល់ពីចម្ការកៅស៊ូរបស់ក្រុមហ៊ុនសុកហ្វីន ខេស៊ីឌី លើសហគមន៍ជនជាតិដើមភាគតិច ក្នុងឃុំប៊ូស្រា ខេត្តមណ្ឌលគិរី", FIDH, ខែតុលា ឆ្នាំ ២០១១ ឧបសម្ពន្ធទី២ (របាយការណ៍របស់FIDH)។

[22] អាចប្រកបថា ព្នង ពូនង។

[23] នៅក្នុងរបាយការណ៍ស្តីពីចីរភាពឆ្នាំ ២០១៧ របស់ខ្លួន, Socfin S.A សំដៅដល់នីតិវិធីនៃការគ្រប់គ្រងការឈើចាប់ខាងក្រៅនៅកម្ពុជាដែលត្រូវបានធ្វើបទបង្ហាញជាផ្លូវការដល់សហគមន៍ និងក្រុមអាជ្ញាធរនៅមូលដ្ឋាន និងរួមមានសេចក្តីសង្ខេបជាភាសាខ្មែរ "របាយការណ៍ស្តីពីចីរភាពឆ្នាំ ២០០៧ កសិកម្មត្រូពិចប្រកបដោយការទទួលខុសត្រូវ" Sofin ទំព័រ ២៧។

បង្ហាញអំពីវិធីសាស្ត្រសម្រាប់ធុរកិច្ចក្នុងការចូលរួមគោរពសិទ្ធិមនុស្សដល់អ្នកចូលរួមដែលរួមមាន អង្គការមិនមែនរដ្ឋាភិបាល ក្រុមហ៊ុនសាជីវកម្ម និងអាជ្ញាធរមូលដ្ឋាន។[24]

- ការអនុម័តលើនីតិវិធីនៃការគ្រប់គ្រងលើបណ្តឹងក្រៅប្រព័ន្ធតុលាការ និងធ្វើបច្ចុប្បន្នភាពដែលជាការជួយគាំទ្រពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជាដែលត្រូវបានបង្ហាញដល់សហគមន៍ជនជាតិដើមភាគតិចជាភាសាមូលដ្ឋានពូនង។[25]
- ការអនុម័តលើគោលនយោបាយគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវដោយដាក់បញ្ចូលសិទ្ធិមនុស្ស និងការគោរពដល់សហគមន៍មូលដ្ឋាននៅក្នុងការងារស្នូលនៅខែមិនា ឆ្នាំ២០១៧[26] និងអនុម័តផែនការការអនុវត្តដែលពាក់ព័ន្ធផ្សេងៗទៀត។[27]
- ខែមករា ឆ្នាំ២០១៧ ការប្តេជ្ញាចិត្តចំពោះការគ្រប់គ្រងចម្ការកៅស៊ូប្រកបដោយចីរភាពក្នុងខេត្តមណ្ឌលគិរី[28]
- ការចូលរួមក្នុងដំណើរការសម្រុះសម្រួលដើម្បីរកដំណោះស្រាយចំពោះវិវាទដីធ្លីដែលបានបន្តចាប់ផ្តើមកាលពីខែវិច្ឆិកា ឆ្នាំ២០១៦។[29]
- ការចុះផ្សាយជាសាធារណៈអំពី "ក្រុមប្រឹក្សាភិបាលតម្លាភាព" ដោយការិយាល័យកណ្តាលរបស់ក្រុមហ៊ុនសុកហ្វីន ខេស៊ីឌី គឺ សុកហ្វីនគ្រុប ដែលបានបង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួននូវវឌ្ឍនភាពពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយគ្រប់គ្រងប្រកបដោយការទំនួលខុសត្រូវដូចជាកំណត់ផែនទីដីសម្បទានសេដ្ឋកិច្ចរបស់ខ្លួន។[30] សុកហ្វីនគ្រុប ក៏បានដាក់ចេញផ្សាយនូវយន្តការដាក់ពាក្យបណ្តឹងក្រៅប្រព័ន្ធតុលាការទាំងឡាយដែលស្ថិតក្រោមនីតិវិធីនៃការគ្រប់គ្រងពាក្យបណ្តឹងក្រៅប្រព័ន្ធតុលាការរបស់ខ្លួន។[31]

---

24 ប្រភព៖ តាមរយៈការទំនាក់ទំនងសារអេឡិចត្រូនិចជាមួយក្រុមហ៊ុនសុកហ្វីន ខេស៊ីឌី។

25 "គោលនយោបាយសម្រាប់ការគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវរបស់ Sofin Group", Sofin, ថ្ងៃទី ២២ ខែមីនា ឆ្នាំ ២០១៧។

26 Sofin នៅប្រទេសកម្ពុជាមានការប្តេជ្ញាចិត្តលើការគ្រប់គ្រង់ប្រកបដោយនិរន្តរភាពលើចំការកៅស៊ូរបស់ខ្លួននៅក្នុងខេត្តមណ្ឌលគិរី សុកហ្វិន ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៧។

27 'ការអនុវត្តគោលនយោបាយផែនការ' ក្រុមហ៊ុនសុកហ្វីន គ្រុប https://www.socfin.com/sites/default/files/2018-11/2017%2007%2010%20Policy%20Implementation%20Plan.pdf.

28 "ក្រុមហ៊ុនសុកហ្វីននៅកម្ពុជាបានប្តេជ្ញាចិត្តសម្រាប់ការគ្រប់គ្រងនិរន្តរភាពនៃចម្ការកៅស៊ូរបស់ខ្លួននៅក្នុងខេត្តមណ្ឌលគិរី" ក្រុមហ៊ុនសុកហ្វីន ថ្ងៃទី៩ ខែមករា ឆ្នាំ២០១៧ https://www.farmlandgrab.org/uploads/attachment/2017-09-01---SOCFIN-Cambodia-commits-to-a-sustainable-management.pdf.

29 "កំណត់ត្រាសង្ខេបស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស៖ ការទប់ស្កាត់ ការកាត់បន្ថយ និងការដោះស្រាយការរំលោភសិទ្ធិមនុស្សនានាពាក់ព័ន្ធនឹងបញ្ហាដីធ្លីក្នុងព្រះរាជាណាចក្រកម្ពុជា៖ ចំណុចកែលម្អទាំងប្រាំពីរយ៉ាង មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ខែធ្នូ ឆ្នាំ២០១៨ https://cchrcambodia.org/index_old.php?title=Briefing-Note-on-Business-and-Human-Rights-Preventing-Mitigating-and-Remedying-Land-Related-Rights-Violations-in-the-Kingdom-of-Cambodia-Seven-Areas-for-Improvement&url=media/media.php&p=analysis_detail.php&anid=83&id=5&lang=eng.

30 ក្រុមហ៊ុនសុកហ្វីន ប៉ាណ្ណូបរិជានស្ទង់តម្លាភាព http://tftmemberdashboard.com/socfin/.

31 ក្រុមហ៊ុនសុកហ្វីន ប៉ាណ្ណូបរិជានស្ទង់តម្លាភាព និងយន្តការក្រៅប្រព័ន្ធតុលាការ http://tftmemberdashboard.com/socfin/progress/grievances/.

- ការអនុម័តគោលនយោបាយប្រឆាំងនឹងពលកម្មកុមារចាប់តាំងពីការចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា និងបទបញ្ញាថ្មីមួយចំនួនដែលហាមឃាត់ក្នុងការជួលបុគ្គលិកថ្មីអាយុក្រោម១៨ឆ្នាំ នៅក្នុងខែតុលា ឆ្នាំ២០១៨។[32]
- ការចូលរួមក្នុងកិច្ចប្រជុំពហុភាគីប្រចាំឆ្នាំដែលបានបង្កើតឡើងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជាក្នុងកំឡុងពេលឆ្នាំ២០១៥ និង២០១៧ ដើម្បីលើកកម្ពស់តម្លាភាពតាមរយៈការចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសម្របសម្រួលដោយតួអង្គផ្សេងៗគ្នា។
- ការកំណត់អត្តសញ្ញាណ ការកំណត់ផែនទី និងការការពារជីសក្ការៈបូជា[33]របស់ជនជាតិដើមភាគតិចពូនងនៅក្នុងដីសម្បទានសេដ្ឋកិច្ចដូចជាដីព្រៃសក្ការៈបូជា ដីកប់សព និងដីព្រៃជំនឿ និងការជួយគាំទ្រដល់ដំណើរការធ្វើប័ណ្ណកម្មសិទ្ធិដីសមូហភាពចាប់តាំងពីឆ្នាំ២០០៩។
- ការជួយគាំទ្រដល់សហគមន៍ដែលនៅជុំវិញចម្ការកៅស៊ូរួមបញ្ចូលទាំងការសាងសង់គ្រឹះស្ថានអប់រំសម្រាប់កុមារដែលជាកូនរបស់និយោជិតបំរើការងារនៅក្នុងចម្ការកៅស៊ូ ហើយជួសជុលសាលារៀនផ្សេងៗទៀត កសាងមណ្ឌលសុខភាពលើដីសម្បទានសេដ្ឋកិច្ច និងជួយគាំទ្រការជួសជុលមណ្ឌលសុខភាពសាធារណៈនៅក្នុងឃុំរួមទាំងការផ្គត់ផ្គង់ទឹកស្អាត និងអគ្គិសនី។[34]
- ចងក្រងរដ្ឋបាលជនជាតិដើមភាគតិចពូនងដែលមានទីតាំងរួមមួយជាទីស្នាក់ការដើម្បីជាភាពងាយស្រួលសម្រាប់រក្សាការទំនាក់ទំនងជាមួយសហគមន៍ពូនង។[35] ក្នុងនោះរួមមានសមាសភាព៣រូបដែលអញ្ជើញមកពីសហគមន៍ជនជាតិដើមភាគតិចពូនង ៣ភូមិផ្សេងៗគ្នាក្នុងឃុំប៊ូស្រា ហើយនិងមានទីស្នាក់ការជាអចិន្ត្រៃយ៍នៅក្នុងក្រុមហ៊ុនសុកហ៊្វីន ខេស៊ីឌី ដូច្នេះសហគមន៍អាចទំនាក់ទំនងដោយផ្ទាល់ជាមួយការិយាល័យក្រុមហ៊ុនសុកហ៊្វីន ខេស៊ីឌី។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

តាមរយៈការចាត់វិធានការសាមញ្ញៗ ធុរកិច្ចនិងរដ្ឋអាចធ្វើឱ្យប្រសើរឡើងចំពោះកំណត់ត្រាសិទ្ធិមនុស្សរបស់ខ្លួន លើកកម្ពស់ការអភិវឌ្ឍដោយនិរន្តរភាព និងសន្សំបានពេលវេលា ថវិកា និងការប្រឹងប្រែងបញ្ចៀស ឬចូលរួមកាត់បន្ថយហានិភ័យសំខាន់ៗដែលបង្កដោយជម្លោះ។

### អនុសាសន៍សម្រាប់ក្រុមហ៊ុនធុរកិច្ច

[32] ក្រុមហ៊ុនសុកហ៊្វីន ខេស៊ីឌី ក្រមសីលធម៌របស់និយោជិត និងក្រមសីលធម៌ធុរកិច្ច (ត្រង់ចំណុចផ្នែកសិទ្ធិមនុស្សនិងកន្លែងការងារ) និងនៅក្នុងគោលនយោបាយផ្ទៃក្នុង (ផ្នែកទី២)។ (ឯកសារផ្លូវការអាចផ្តល់ជូនបានបើមានការស្នើសុំ)។
[33] របាយការណ៍ស្តីពីនិរន្តរភាពរបស់ក្រុមហ៊ុនសុកហ៊្វី ឆ្នាំ២០១៧ ទំព័រទី២៩។
[34] របាយការណ៍ស្តីពីនិរន្តរភាពរបស់ក្រុមហ៊ុនសុកហ៊្វី ឆ្នាំ២០១៧ ទំព័រទី១៤ ដល់ ១៥។
[35] របាយការណ៍ស្តីពីនិរន្តរភាពរបស់ក្រុមហ៊ុនសុកហ៊្វី ឆ្នាំ២០១៧ ទំព័រទី២៨។

ទី១ ធ្វើការត្រួតពិនិត្យដ៏ត្រឹមត្រូវ មុនពេលចាប់ផ្តើមប្រតិបត្តិការណាមួយនៅក្នុងប្រទេសកម្ពុជា ដោយយោងតាមគោលការណ៍លេខ ១៥ ១៧ និង១៨ នៃគោលការណ៍ណែនាំ។

ទី២ អនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដោយចែករំលែកលទ្ធផលដល់សហគមន៍រងផលប៉ះពាល់និងសាធារណជនឱ្យទាន់ពេលវេលានិងមានយន្តការតាមដានការអនុវត្តរបស់ខ្លួនដោយអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដូចជាគោលការណ៍លេខ១៨ នៃគោលការណ៍ណែនាំ និងអនុវត្តតាមលក្ខខណ្ឌតម្រូវរបស់ អាយ អេហ្វ ស៊ី[36]។

ទី៣ កំណត់អត្តសញ្ញាណសហគមន៍រងផលប៉ះពាល់ជានាការប្រឹក្សាយោបល់ប្រកបដោយអត្ថន័យ និងគោរពតាមគោលការណ៍នៃការយល់ព្រមដោយពេញចិត្ត ដោយប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ ព្រមទាំងចូលរួមជាមួយសហគមន៍រងផលប៉ះពាល់ និងអង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធនឹងការដោះស្រាយវិវាទដីធ្លីនេះ។

ទី៤ ដោះស្រាយប្រកបដោយប្រសិទ្ធភាពចំពោះការរំលោភបំពានសិទ្ធិមនុស្សទាំងអស់ និងប្រាកដថាដំណោះស្រាយនោះបំពេញតាមលក្ខខណ្ឌតម្រូវអំពីប្រសិទ្ធភាពនៃគោលការណ៍លេខ៣១ នៃគោលការណ៍ណែនាំ។

## អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា

ទី៥ តម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមច្បាស់លាស់មុនពេល អនុញ្ញាតឱ្យមានគម្រោងហេដ្ឋារចនាសម្ព័ន្ធ គម្រោងអភិវឌ្ឍន៍ ឬតំបន់សេដ្ឋកិច្ចពិសេសណាមួយ ដោយតម្រូវថាការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ត្រូវចែកដល់សហគមន៍រងផលប៉ះពាល់ និងសាធារណជនឱ្យទាន់ពេលវេលានិងទាមទារ ឱ្យមានយន្តការតាមដានការអនុវត្តដោយអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិរួមមានគោលការណ៍លេខ១៨ នៃគោលការណ៍ណែនាំ និងគោលការណ៍ អាយ អេហ្វ ស៊ី ព្រមទាំង គិតគូឡើងវិញអំពីកិច្ចសន្យារបស់ក្រុមហ៊ុន ដែលប្រតិបត្តិការសម្បទានដីសេដ្ឋកិច្ច ឬតំបន់សេដ្ឋកិច្ចតម្រូវឱ្យក្រុមហ៊ុនណា ដែលមិនបានអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ដើម្បីបង្កើតផែនការកាត់បន្ថយចំពោះហានិភ័យនានាដែលបានរកឃើញ និងតាមដានការអនុវត្តទាំងនោះ ក៏ដូចជាទាមទារឱ្យពួកគេផ្តល់ដំណោះស្រាយមានប្រសិទ្ធភាពផងដែរ។

ទី៦ គួរពិចារណាលើកិច្ចសន្យាជាមួយក្រុមហ៊ុន ដែលប្រតិបត្តិការលើដីសម្បទានសេដ្ឋកិច្ច ឬតំបន់សេដ្ឋកិច្ចពិសេសតម្រូវឱ្យក្រុមហ៊ុនទាំងនោះដែលមិនទាន់បញ្ចប់ការសិក្សាវាយតម្លៃហេតុប៉ះពាល់សង្គមសម្រាប់

---

[36] យោងតាមសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ("អាយ អេហ្វ ស៊ី") ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមត្រូវរួមបញ្ចូលគម្រោងគ្រប់គ្រងសង្គមនិងបរិស្ថាន (គឺជាគម្រោងដ៏ត្រឹមត្រូវមួយ) ដែលកំណត់ធនធាន តួនាទី ការទទួលខុសត្រូវ ដែលតម្រូវឱ្យមានដើម្បីគ្រប់គ្រងផលប៉ះពាល់ដែលបានកំណត់ទុកនៅក្នុងការវាយតម្លៃហាតុប៉ះពាល់បរិស្ថាននិងសង្គម រួមទាំងអនុវត្តវិធានការកាត់បន្ថយ។ គម្រោងនេះត្រូវរួមបញ្ចូលទាំងការពិពណ៌នាអំពីសកម្មភាពទាំងឡាយដែលបានគ្រោងទុកដើម្បីកាត់បន្ថយផលប៉ះពាល់ គម្រោងពេលវេលា និងការកំណត់ធនធាន រួមទាំងគម្រោងទំនាក់ទំនងដែលចង្អុលបង្ហាញពីវឌ្ឍនភាពនៃការអនុវត្ត និងតម្រូវការត្រួតពិនិត្យនានា។ សូមចូលមើលគេហទំព័រ អាយ អេហ្វ ស៊ី 'ការណែនាំអំពីចម្រុះវិស័យសម្រាប់វិស័យឯកជន ដំណើរការវាយតម្លៃហាតុប៉ះពាល់សង្គម និងបរិស្ថាន' https://www.ifc.org/wps/wcm/connect/296ae980488551f5aa0cfa6a6515bb18/ESIA.pdf?MOD=AJPERES.

ដាក់ចេញនូវផែនការកាត់បន្ថយលើហានិភ័យដែលត្រូវបានកំណត់ និងធ្វើការឃ្លាំមើលពីការអនុវត្តរបស់ខ្លួន និងទាមទារឱ្យពួកគេផ្ដល់នូវដំណោះស្រាយប្រកបដោយប្រសិទ្ធិភាព។

ទី៧ ប្រាកដថាមានការប្រឹក្សាយោបល់ប្រកបដោយអត្ថន័យជាមួយសហគមន៍ ដែលរងផលប៉ះពាល់ពីវិវាទដីធ្លីមុនពេលផ្ដល់កិច្ចសន្យាណាមួយ និងធានាថាពួកគាត់ នៅតែបន្តចូលរួមការវាយតម្លៃអំពីការអភិវឌ្ឍព្រមទាំងធានាឱ្យគោរពតាមគោលការណ៍នៃការយល់ព្រមដោយពេញចិត្ត ដោយប្រាប់ឱ្យដឹងមុននិងទទួលបានព័ត៌មានពេញលេញផងដែរ។

ទី៨ បង្កើត និងអនុវត្តផែនការសកម្មភាពថ្នាក់ជាតិស្ដីពីធុរកិច្ច និងសិទ្ធិមនុស្ស ដោយសហការជាមួយសង្គមស៊ីវិលដើម្បីផ្សព្វផ្សាយ និងអនុវត្តគោលការណ៍ណែនាំ។

ទី៩ ដោះស្រាយប្រកបដោយប្រសិទ្ធភាពចំពោះការរំលោភបំពានសិទ្ធិមនុស្សទាំងអស់ និងប្រាកដថាដំណោះស្រាយនោះបំពេញតាមលក្ខខណ្ឌតម្រូវអំពីប្រសិទ្ធភាពនៃគោលការណ៍លេខ៣១នៃគោលការណ៍ណែនាំ។

ទី១០ ធានាថាការដោះស្រាយវិវាទដីធ្លីទាន់ពេលវេលា ដោយអនុលោមតាមបទដ្ឋានអន្តរជាតិប្រការ ៣ (ក) នៃ ក.អ.ស.ព.ន និងគោលការណ៍លេខ២៦ នៃគោលការណ៍ណែនាំ។

ទី១១ ធានាថា ដំណោះស្រាយជាសំណងប៉ះប៉ូវត្រូវគោរពតាមបទដ្ឋានអន្តរជាតិ រួមមានគោលការណ៍ និងគោលការណ៍ណែនាំមូលដ្ឋានអំពីការបណ្ដេញចេញ និងការបំលាស់ទីលំនៅ ដោយផ្អែកលើការអភិវឌ្ឍ និងបំពេញតាមលក្ខខណ្ឌតម្រូវអំពីប្រសិទ្ធភាពនៃគោលការណ៍លេខ៣១ នៃគោលការណ៍ណែនាំ។

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងលោក វណ្ណ សុផាត អ្នកសម្របសម្រួលគម្រោងធុរកិច្ច និងសិទ្ធិមនុស្សនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាតាមរយៈទូរស័ព្ទលេខ (+៨៥៥) (០) ១២ ៩៤១ ២០៦ ឬអ៊ីម៉ែល vann.sophath@cchrcambodia.org.**

---ចប់---